# អនុក្រឹត្យលេខ ៣៣ អនក្រ
# ស្តីពីការបង្កើតគណៈកម្មការ ពិនិត្យការដេញថ្លៃ
# និងការសាងសង់ព្រលានយន្តហោះ ពោធិចិនតុង

*រាជធានីភ្នំពេញ, ថ្ងៃទី៩ខែ កក្កដា ឆ្នាំ១៩៩៤*

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហានុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សំរេច

**មាត្រា ១** : បង្កើតគណៈកម្មការត្រួតពិនិត្យការដេញថ្លៃអន្តរជាតិ និង ការសាងសង់ព្រលានយន្តហោះពោធិចិនតុងដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ត្រាំ អ៊ីវតឹក អនុរដ្ឋលេខាធិការ ក្រសួងសាធារណៈការ និង ដឹកជញ្ជូនប្រធាន

២- ឯកឧត្តម ម៉ុក សំអែល អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កម្ពុជា អនុប្រធាន

៣- ឯកឧត្តម ម៉ម សុផាណា ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

៤- ឯកឧត្តម សុខ ចិន្តា អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៥- ឯកឧត្តម គៀង វ៉ាង អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ សមាជិក

៦- លោក GANS BRUYNTJES ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹង គៀត សមាជិក

៧- លោក កៅ អ៊ិន ហុង ទីប្រឹក្សាច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- លោក ឆយ វិសលាភ ប្រធានការិយាល័យគ្រប់គ្រងទុន និង វិនិយោគ- [illegible] ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៩- លោក ស្មៀង ហាក់ អគ្គនាយក ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១០- លោក រស់ ម៉ូរ៉ាត ស្ថាបត្យករ សមាជិក

១១- តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១២- លោក ឈិត ម៉ុណ្ណា នាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

មាត្រា ២ : គណៈកម្មការនេះមានភារកិច្ចពិនិត្យ និង ជ្រើសរើសអ្នកវិនិយោគទុនដែលត្រូវ អនុញ្ញាតឲ្យសាងសង់ព្រលានយន្តហោះពោធិ៍ចិនតុង ។

មាត្រា ៣ : ក្រសួងសាធារណការ និង ដឹកជញ្ជូននិងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ទទួលបន្ទុកក្នុងការរៀបចំសិទ្ធិសញ្ញា និង ការត្រួតពិនិត្យក្នុងការសាងសង់អោយបានគ្រប់គ្រាន់តាមលក្ខណៈបច្ចេកទេស ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃ ក្រសួងរដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *